## ទិវាអន្តរជាតិ ដើម្បីគាំទ្រជនរងគ្រោះនៃអំពើទារុណ្ឌកម្ម

## ក្រុមអ្នកការពារសិទ្ធិមនុស្សអំពាវនាវអោយអោយរដ្ឋាភិបាលកម្ពុជាអនុវត្តតាមអនុសញ្ញា ប្រឆាំងនិងអំពើទារុណ្ឌកម្ម របស់អង្គការសហប្រជាជាតិ

ភ្នំពេញថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១០ - នៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១០ជា ថ្ងៃគំរប់រយះពេល ២៣ឆ្នាំ ចាប់តាំងពីអនុសញ្ញាប្រឆាំងអំពើទារុណ្ឌកម្មរបស់អង្គការសហប្រជាជាតិបានចូលជាធរមាន។ មានរដ្ឋចំនួន ១៤៦ ដែលបានចូលជាភាគី នៃអនុសញ្ញាជាប្រវត្តិសាស្ត្រនេះ បានធានាថា ការពារ ផ្តន្ទាទោស និង ផ្តល់សំណងដល់ជនរងគ្រោះដោយសារអំពើទារុណ្ឌកម្ម និងធានាថា នឹងបញ្ឈប់មិនអោយមាននិទន្តភាព ដែលជាឧក្រិដ្ឋកម្មដ៏អាក្រក់បផុត ត្រូវបានគេស្គាល់ជាទូទៅក្នុងចំណោមមនុស្សជាតិ។

ថ្ងៃនេះ យើងខ្ញុំសូមសំដែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការកើតឡើងនៃអំពើទារុណ្ឌកម្ម និង ការធ្វើបាបដែលត្រូវបានហាមឃាត់ មិនមានការស៊ើបអង្កេត ការផ្តន្ទាទោស និង ការដាក់ទណ្ឌកម្មទៅលើអំពើឧក្រិដ្ឋកម្មទាំងនេះទេ។

ថ្ងៃនេះយើងសូមសំដែងអោយឃើញនូវការសាមគ្គីភាពជាមួយនឹងជនរងគ្រោះ នៃអំពើទារុណ្ឌកម្មនៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងពិភពលោកទាំងមូល។

ប្រទេសកម្ពុជាបានចូលជាភាគីនៃអនុសញ្ញានេះនៅឆ្នាំ១៩៩២។ ហើយនៅឆ្នាំ២០០៧ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័ណលើពិធីសារបន្ថែម នៃអនុសញ្ញានេះ ជាជំហ៊ានវិជ្ជមានមួយមួយដែលប្រទេសកម្ពុជា បានទទួលយកកតព្វកិច្ចបន្ថែម ដើម្បីបង្កើតនូវយន្តកាការពារថ្នាក់ឯករាជ ដើម្បីតាបដាន មើលគ្រប់មន្ទីឃុំឃាំងទាំងអស់ក្នុងគោលបំណង ដើម្បីការពារអំពើរទារុណកម្មនៅក្នុងប្រទេសកម្ពុជា។

នៅថ្ងៃទី២៦ ខែមិថុនា គឺជារយះពេលមួយខែ មុនពេលដែលអង្គជំនុំជម្រះវិសាមញ្ញ នៃតុលាការកម្ពុជាដល់ពេលកំណត់ ដើម្បីប្រកាសសាលក្រមលើកទីមួយរបស់ខ្លួនសំរាប់ករណី ០០១ ជាករណីដែលទាក់ទងទៅនិងការប្រើប្រាស់អំពើរទារុណកម្មដែលមានក៏រិតធំធេង និង ល្បីសុះសាយអាក្រក់ជាទីបំផុត នៅឯទួលស្លែង ជាពន្ធនាគារសន្តិសុខ "ស២១" ដែលត្រូវបានគេប្រើប្រាស់នៅក្នុងសម័យកាលនៃរបបខ្មែរក្រហម។

ដោយយល់ព្រមតម្រូវឱ្យមានកតព្វកិច្ចតាមអនុសញ្ញាប្រឆាំងអំពើទារុណកម្មនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការដ៏មានសរៈសំខាន់ ដើម្បីបញ្ចប់អំពើរទារុណកម្ម។ នៅក្នុងស្មារតី នៃការប្តេជ្ញាចិត្តនេះ យើងខ្ញុំសុំអំពាវនាវ ដល់រាជរដ្ឋាភិបាលកម្ពុជាដូចតទៅនេះ :

- សូមសហការអោយបានពេញលេញ ជាមួយនឹងគណៈកម្មាធិកាប្រឆាំងអំពើទារុណកម្ម របស់អង្គការសហប្រជាជាតិ ដែលនឹងពិនត្យរបាយការណ៍ តាមកាលកំណត់លើកទីពីរ របស់ប្រទេសកម្ពុជា នៅខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីវិធានការណ៍ដែលត្រូវធ្វើឡើងដើម្បីធ្វើឱ្យកាព្វតកិច្ចរបស់ខ្លួន មានប្រសិទ្ធិភាពតាមរយៈអនុសញ្ញានេះ ហើយនិងអនុវត្តអោយបានយ៉ាងពេញលេញ នូវសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិកា
- សូមប្រកាស ដោយយោងលើមាត្រា២២ នៃអនុសញ្ញានេះថា ខ្លួន ទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិកា ដើម្បីទទួលនិងពិចារណារាល់ការទំនាក់ទំនងពីបុគ្គល ឬក្នុងនាមបុគ្គលស្រមទៅតាម យុត្តាធិការរបស់ខ្លួនចំពោះនរណាដែលអះអាងខ្លួនជាជនរងគ្រោះនៃការរំលោភបំពានក្នុងបញ្ញត្តិនៃអនុសញ្ញានេះ
- សូមធានាថា យន្តការការពារថ្នាក់ជាតិ ដែលបានបង្កើតឡើងដោយយោងលើពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងនឹងទារុណកម្ម គឺឯករាជ្យ និងមិនលំអៀង និង អាចទទួលទទួលពាក្យបណ្តឹងបុគ្គលទាក់ទងនឹងអំពើទារុណកម្មនិងការធ្វើបាបដែលត្រូវបានហាមឃាត់ផ្សេងៗ ដែលបន្ទាប់មកអាចនាំយកពាក្យបណ្តឹងឱ្យទៅអាជ្ញាធរមានសមត្ថកិច្ចធ្វើការតាមដានបន្ត
- សូមធានាថា ទារុណកម្មគឺត្រូវបានទទួលស្គាល់ថា ជាឧក្រិដ្ឋកម្មក្នុងប្រទេសកម្ពុជាដោយយោងលើ និយមន័យ ដែលមានចែងក្នុងមាត្រា១ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្មរបស់អង្គការសហប្រជាជាតិ។ រដ្ឋាភិបាលកម្ពុជា គួរធ្វើការប្រកាសជាផ្លូវការណ៍ថា និយមន័យទារុណកម្មមានចែងក្នុងមាត្រា១ នៃអនុសញ្ញារួមទាំងបទបញ្ញត្តិទាំងឡាយ នៃអនុសញ្ញានេះ គឺអាចអនុវត្តបានដោយផ្ទាល់ក្នុងប្រទេសកម្ពុជា ដោយស្របតាមច្បាប់នៃប្រទេសកម្ពុជា។ លើសពីនេះទៀត ដើម្បីផ្តលនូវនូវភាពច្បាប់លាស់បំផុតដល់អាជ្ញាធរសមត្ថកិច្ចកម្ពុជា រដ្ឋាភិបាលកម្ពុជា និង រដ្ឋសភាជាតិ គួរចាត់វិធានការចាំបាច់ដើម្បីធានាថា និយមន័យទារុណកម្មក្នុងក្រមព្រហ្មទណ្ឌកម្ពុជា គឺត្រូវធ្វើអោយស្របជាមួយនឹងនិយមន័យក្នុងមាត្រា១ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម។ ច្បាប់ដែលកំណត់អោយអំពើទារុណកម្ម ជាបទឧក្រិដ្ឋ ត្រូវបានដាក់ចូលជាធរមានឱ្យបានឆាប់។
- សូមបង្កើតមធ្យោបាយ ដែលមានប្រសិទ្ធិភាព និងងាយស្រួលទំនាក់ទំនងសំរាប់ជារងគ្រោះ ដាក់ពាក្យបណ្តឹង អំពីអំពើទារុណកម្ម និងអំពើធ្វើបាបដែលបានហាមឃាត់ផ្សេងៗទៀត ជាមួយ នឹងអាជ្ញាធរមានសមត្ថកិច្ច និងធានាថា អាជ្ញាធរនោះនឹងធ្វើការស៊ើបអង្កេតយ៉ាងឆាប់រហ័ស លើបណ្តឹងទាំងនោះ ដោយ

យោងទៅលើអនុសញ្ញា និង កន្លែងណាដែលមានភស្តុងតាងគ្រប់គ្រាន់ត្រូវធានាថា ជនត្រូវចោទពីបទទារុណកម្មទាំងនោះត្រូវបានកាត់ទោស ។

- សូមធ្វើអោយបានប្រាកដថា ត្រូវមានសេវាកម្មផ្លូវចិត្ត និងរាងកាយមានគ្រប់គ្រាន់សំរាប់ជនរងគ្រោះនៃទារុណកម្ម ព្រមទាំងមានវិធានការសំណងដ៏មានប្រសិទ្ធិភាព និងគ្រប់គ្រាន់ផងដែ ។

☏ សំរាប់ព័តិមានបន្ថែមសូមទាក់ទង:


| | | |
|---|---|---|
| លោក សុក សំអឿន | ប្រធានសំរបសំរួលស្ដីទី CHRAC/ នាយកប្រតិបត្តិអង្គការ CDP<br>ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ | |
| លោក ធន សារាយ | ប្រធានសមាគមអាដហុក (ADHOC) | ទូរស័ព្ទលេខ: ០១៦ ៨៨0 ៥0៩ |
| លោកស្រី ស៊ុន ចាន់សែន | ប្រធានសមាគម KYA | ទូរស័ព្ទលេខ: ០១៧ ៧៨៨ ៩៥៥ |
| លោកស្រី សយ សារាវឌ្ឍនី | នាយិកាប្រតិបត្តិអង្គការ CWCC | ទូរស័ព្ទលេខ: 0៩២ ៩៩៣ ៣៥៨ |
| Ms. Carla Fershman | Director of REDRESS | Email: carla@redress.org |
| Mr. Basil Fernando | Director of AHRC | Tel: 852 26986367 |